**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ០៦៦-សណ.១៧ អអក

ភ្នំពេញ, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អឹម អេស ភី ឌីវ៉ែលឡុបមិន កូអិលធីឌី សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ខេត្តប៉ៃលិន

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ខេត្តប៉ៃលិន ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ០០៩ អ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ ឲ្យក្រុមហ៊ុន អឹម អេស ភី ឌីវ៉ែលឡុបមិន កូអិលធីឌី សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ខេត្តប៉ៃលិន ក្នុងអាណត្តិមុនគឺ ១០ឆ្នាំ ។ ដោយពិនិត្យឃើញថា ក្នុងអាណត្តិនេះក្រុមហ៊ុន អឹម អេស ភី ឌីវ៉ែលឡុបមិន កូអិលធីឌី បានសាងសង់ និងកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន អឹម អេស ភី ឌីវ៉ែលឡុបមិន កូអិលធីឌី ដោយផ្តល់អាណត្តិអាជ្ញាបណ្ណចំនួន ១៥(ដប់ប្រាំ)ឆ្នាំ បន្តទៀត ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ................. ......................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ខេត្តប៉ៃលិន ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណក្រុមហ៊ុន អឹម អេស ភី ឌីវ៉ែលឡុបមិន កូអិលធីឌី អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។ល។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.និ នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី៥
## លើឯកសារអាជ្ញាបណ្ណលេខ ០០៩ ឯអ ចុះថ្ងៃ២៧ ខែឧសភា
## ឆ្នាំ២០០២ សម្រាប់ក្រុមហ៊ុន អឹម អេស ភី ឌីវ៉េលឡុបមិន
## ភូអិលធីឌី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃ
## ស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ខេត្តប៉ៃលិន

## សម្រាប់ការបន្តអាណត្តិអាជ្ញាបណ្ណ

**DECISION ON THE FIFTH REVISION**

OF THE LICENSE DOCUMENT No. 009 LD DATED MAY 27, 2002 OF
M.S.P DEVELOPMENT CO., LTD FOR PROVIDING ELECTRIC POWER
SERVICE AT SOME PARTS OF SALAKRAO DISTRICT
AND KRONG PAILIN, PAILIN PROVINCE

**FOR RENEWAL OF TERM OF LICENSE**

ថ្ងៃទី... ខែ... ឆ្នាំ២០១៧

**..., 2017**